## រាជរដ្ឋាភិបាលកម្ពុជា

ក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្ត

# គោលនយោបាយអភិវឌ្ឍន៍វិស័យ ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥

"តម្រង់ទិសទីផ្សារ និងបង្កើតលក្ខខណ្ឌអំណោយផលដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម"

បានទទួលការឯកភាពពីរាជរដ្ឋាភិបាល
នាថ្ងៃពុធ ១២កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០

# មាតិកា


**១. សេចក្តីផ្តើម** ........................................ ១

**២. ក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥** (IDP) ........................................ ១

២.១. គោលបំណង ........................................ ១

២.២. វិធីសាស្ត្រក្នុងការរៀបចំប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្ត IDP (IDP M&E System) ....... ១

២.៣. ការរៀបចំសូចនាករគន្លឹះ (Key Indicator) និងសូចនាករគោល (Milestone Indicator) ........ ៣

២.៤. ការប្រមូល និងគ្រប់គ្រងទិន្នន័យ ........................................ ៤

២.៥. ការរៀបចំរបាយការណ៍ និងគណនេយ្យភាព ........................................ ៤

**៣. បញ្ហាប្រឈម និងហានិភ័យ** ........................................ ៥

**៤. សេចក្តីសន្និដ្ឋាន** ........................................ ៦

**ឧបសម្ព័ន្ធទី១**

**ឧបសម្ព័ន្ធទី២**

**ឧបសម្ព័ន្ធទី៣**

**ឧបសម្ព័ន្ធទី៤**


លិខិតលេខ ១៧៥០ សហវ.គសហ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី របាយការណ៍កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) ស្តីពីការពិនិត្យលើ "សេចក្តីព្រាងវឌ្ឍនភាពនៃការអនុវត្ត IDP ក្នុងឆ្នាំ២០១៧-២០១៨"

លិខិតលេខ ២២៤៣/២០ ក.អ.ក. ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពី សំណើសុំដាក់ឆ្លង "ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្ត IDP" ក្នុងកិច្ចប្រជុំ គ.ស.ហ.

លិខិតលេខ ៥៩៦៧ សហវ.គសហ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី ករណីសំណើសុំឆ្លង "ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្ត IDP" ក្នុងកិច្ចប្រជុំ គ.ស.ហ.

លិខិតលេខ ៨៨៤៧ សហវ.គសហ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី របាយការណ៍លទ្ធផលកិច្ចប្រជុំ គ.ស.ហ. ស្តីពី "ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្ត IDP"

## ក្របខណ្ឌតាមដាន និងវាយតម្លៃ
## ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (IDP)

### ១. សេចក្តីផ្តើម

ក្នុងទិសដៅឈានទៅសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជានៅឆ្នាំ២០៣០ រាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (IDP) ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មីរបស់កម្ពុជា ផ្តោតសំខាន់លើការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។ ដើម្បីធានាវឌ្ឍនភាពជាប្រចាំ ប្រសិទ្ធភាព និងសង្គតិភាព នៃការអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) ក្នុងការរៀបចំ និងសម្របសម្រួលអនុវត្តឱ្យមានប្រសិទ្ធភាពនូវប្រព័ន្ធតាមដាននិងវាយតម្លៃដ៏ពេញលេញ និងគ្រប់ជ្រុងជ្រោយមួយ។ ជាក់ស្តែង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត IDP ប្រចាំឆ្នាំ ពីរលើករួចមកហើយ គឺរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត IDP គិតត្រឹមខែធ្នូ ឆ្នាំ២០១៦ និងក្នុងឆ្នាំ២០១៧-២០១៨ ព្រមទាំងទទួលបានការអនុម័តពីកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ ការរៀបចំរបាយការណ៍វឌ្ឍនភាពទាំងពីរលើក កន្លងមកគឺជាការប្រមូលសរុបរបាយការណ៍ផ្តល់ដោយក្រសួង ស្ថាប័ន និងរដ្ឋបាល ថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដែលមានលក្ខណៈជាការរៀបរាប់ពីការអនុវត្តសកម្មភាពនានាពាក់ព័ន្ធនឹង IDP ជាជាងការវិភាគដោយផ្អែកលើសូចនាករច្បាស់លាស់ និងពុំមានក្របខណ្ឌ និងប្រព័ន្ធតាមដាននិងវាយតម្លៃនៅឡើយ។ ក្នុងន័យនេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានរៀបចំក្របខណ្ឌតាមដាន និងវាយតម្លៃ ដែលជាត្រីវិស័យក្នុងការរៀបចំប្រព័ន្ធតាមដាន និងវាយតម្លៃសម្រាប់ប្រើប្រាស់ក្នុងការវាយតម្លៃពាក់កណ្តាលអាណត្តិ ការតាមដានវឌ្ឍនភាពប្រចាំឆ្នាំ និងការវាយតម្លៃចុងអាណត្តិ នៃការអនុវត្ត IDP។

### ២. ក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្ត IDP

#### ២.១. គោលបំណង

គោលបំណងចម្បងនៃការបង្កើតក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្ត IDP រួមមាន៖

- រៀបចំឱ្យមានប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្ត IDP (IDP M&E System) គ្រប់ជ្រុងជ្រោយមួយ
- កំណត់អំពីដំណើរការ វិធីសាស្ត្រ យន្តការ និងស្ថាប័នទទួលខុសត្រូវក្នុងការរាយការណ៍ គ្រប់គ្រង និងវិភាគទិន្នន័យ និងការរៀបចំរបាយការណ៍តាមដាន និងវាយតម្លៃ
- កំណត់ពីបញ្ហាប្រឈម និងហានិភ័យក្នុងការតាមដាន និងវាយតម្លៃ។

#### ២.២. វិធីសាស្ត្រក្នុងការរៀបចំប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្ត IDP (IDP M&E System)

គោលនយោបាយ IDP ត្រូវបានបង្កើតឡើងដោយផ្អែកលើទ្រឹស្តីបរិវត្តកម្ម (Theory of Change) ក្នុងការជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា រួមមាន (១) ការប្រែក្លាយឧស្សាហកម្មកម្ពុជាឱ្យក្លាយជាឧស្សាហកម្មផ្អែកលើជំនាញ ដោយសម្រេចឱ្យបាននូវគោលដៅទាំង៣ ដែលជាបច្ច័យរយៈពេលវែង ក្នុងកម្រិត

យុទ្ធសាស្ត្រ, (២) ការកំណត់ក្របខណ្ឌយុទ្ធសាស្ត្រ រួមមានយុទ្ធសាស្ត្រគន្លឹះ ដែលមានសសរស្តម្ភបួន (ការជំរុញការវិនិយោគ, ការធ្វើទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម, ការពង្រឹងបរិស្ថាននិយតកម្ម, និងការសម្របសម្រួលគោលនយោបាយគាំទ្រ), វិសាលភាព និងវិស័យអាទិភាព, និងអភិក្រមនៃការអនុវត្ត ដែលជាលទ្ធផលកម្រិតវិស័យ ត្រូវសម្រេចបានក្នុងរយៈពេលមធ្យម, និង (៣) ការអនុវត្តវិធានការគន្លឹះបួនជាក់ស្តែង និងវិធានការគោលនយោបាយ ដែលជាសកម្មភាពត្រូវអនុវត្តក្នុងកម្រិតបច្ចេកទេស។ ដើម្បីអាចវាស់វែង និងវាយតម្លៃការអនុវត្ត IDP ឱ្យបានច្បាស់លាស់ ចាំបាច់ត្រូវរៀបចំផ្នែកសំខាន់ៗទាំងបីខាងលើនៃ IDP ចូលទៅក្នុងរចនាសម្ព័ន្ធនៃប្រព័ន្ធតាមដាន និងវាយតម្លៃ (សេចក្តីពន្យល់បន្ថែមអំពីវិធីសាស្ត្រក្នុងការរៀបចំ មានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធទី២)។

ការតាមដាន និងវាយតម្លៃការអនុវត្ត IDP បានចែកចេញជា ៣ កម្រិត គឺកម្រិតយុទ្ធសាស្ត្រឬកម្រិតម៉ាក្រូ, កម្រិតវិស័យ, និងកម្រិតបច្ចេកទេសឬប្រតិបត្តិ។ កម្រិតយុទ្ធសាស្ត្រឬកម្រិតម៉ាក្រូ ផ្តោតលើចក្ខុវិស័យ រួមទាំងគោលបំណង និងគោលដៅ ជាលទ្ធផលចុងក្រោយ ឬរយៈពេលវែង (Final Outcome) ដែលជាបច្ច័យចូលរួមក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ កម្រិតវិស័យ ផ្តោតលើក្របខណ្ឌយុទ្ធសាស្ត្រ ជាលទ្ធផលបន្ទាប់ ឬរយៈពេលមធ្យម (Immediate Outcome) នៃគោលនយោបាយ។ កម្រិតបច្ចេកទេសឬប្រតិបត្តិ ផ្តោតលើវិធានការគន្លឹះបួនជាក់ស្តែង និងវិធានការគោលនយោបាយនិងផែនការសកម្មភាព ជាលទ្ធផលដំបូង ឬរយៈពេលខ្លី (Outputs)។

**តារាងទី១÷រចនាសម្ព័ន្ធក្នុងការតាមដាននិងវាយតម្លៃ**

| កម្រិត | រចនាសម្ព័ន្ធ និងផ្នែកនៃ IDP | ការរៀបចំក្នុងប្រព័ន្ធតាមដាននិងវាយតម្លៃ | ប្រភេទលទ្ធផល |
|---|---|---|---|
| កម្រិតយុទ្ធសាស្ត្រ ឬកម្រិតម៉ាក្រូ | - ចក្ខុវិស័យ (១)<br>- គោលបំណងនិងគោលដៅ (៣) | - គោលដៅអភិវឌ្ឍន៍ជាតិ (៣)<br>- ចក្ខុវិស័យ (១)<br>- គោលបំណង និងគោលដៅ (៥) | លទ្ធផលចុងក្រោយ ឬរយៈពេលវែង |
| កម្រិតវិស័យ | - ក្របខណ្ឌយុទ្ធសាស្ត្រ (យុទ្ធសាស្ត្រគន្លឹះទាំង៤, វិសាលភាព និងវិស័យអាទិភាព, និងអភិក្រមនៃការអនុវត្ត) | - អន្តរាគមន៍គោលនយោបាយ (២០) | លទ្ធផលបន្ទាប់ ឬរយៈពេលមធ្យម |
| កម្រិតបច្ចេកទេស ឬកម្រិតប្រតិបត្តិ | - វិធានការគន្លឹះជាក់ស្តែង (៤)<br>- វិធានការគោលនយោបាយ (១១៩) | - វិធានការគោលនយោបាយ (១២៣) | លទ្ធផលដំបូង ឬរយៈពេលខ្លី |

ប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្ត IDP ប្រើប្រាស់នូវឧបករណ៍ចំនួន ៣ ដូចខាងក្រោម÷

**(១) តក្កកម្មអន្តរាគមន៍ (Intervention Logic)** គឺជាឧបករណ៍បង្ហាញពីរចនាសម្ព័ន្ធគោលនៃទំនាក់ទំនងរវាងយុទ្ធសាស្រ្តគន្លឹះឬផ្នែកអន្តរាគមន៍គោលនយោបាយ (Intervention Areas) ជាមួយនឹងគោលបំណង, គោលដៅ និងចក្ខុវិស័យនៃ IDP ព្រមទាំងភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍ជាតិ ដែលជាបច្ច័យរយៈពេលវែងផងដែរ។

**(២) ក្របខណ្ឌតក្កកម្ម (Log-frame)** គឺជាតារាងលម្អិត ដែលបង្ហាញនូវគ្រប់វិធានការគោលនយោបាយរបស់ IDP, ក្របខណ្ឌយុទ្ធសាស្រ្ត (អន្តរាគមន៍គោលនយោបាយ), និងគោលបំណងនិងចក្ខុវិស័យនៃ IDP។ លទ្ធផលនៃការអនុវត្តវិធានការគោលនយោបាយ គឺជាលទ្ធផលរយៈពេលខ្លី ដែលត្រូវវាយតម្លៃក្នុងកម្រិតបច្ចេកទេស, លទ្ធផលនៃការអនុវត្តក្របខណ្ឌយុទ្ធសាស្រ្ត ឬអន្តរាគមន៍គោលនយោបាយ គឺជាលទ្ធផលរយៈពេលមធ្យម ដែលត្រូវវាយតម្លៃក្នុងកម្រិតវិស័យ, និងលទ្ធផលនៃការសម្រេចចក្ខុវិស័យ និងគោលបំណង/គោលដៅរបស់IDP គឺជាលទ្ធផលរយៈពេលវែង ដែលត្រូវវាយតម្លៃក្នុងកម្រិតយុទ្ធសាស្រ្ត។ ក្របខណ្ឌតក្កកម្ម ជាឧបករណ៍មួយដែលកំណត់ថាតើគោលនយោបាយ IDP នឹងត្រូវវាស់វែង «ដោយរបៀបណា» តាមរយៈការកំណត់នូវសូចនាករគន្លឹះ (KPIs) ដែលអាចវាស់វែងបានយ៉ាងច្បាស់លាស់។

**(៣) ទម្រង់គំរូរបាយការណ៍ (Report Template Format - RTF)** គឺជាឧបករណ៍ដែលដាក់បញ្ចូលនូវរាល់វិធានការគោលនយោបាយ រួមមានវិធានការគន្លឹះបួនជាក់ស្តែង និងវិធានការគោលនយោបាយទាំង១១៩ ដែលបានកំណត់នៅក្នុងម៉ាទ្រីសនៃឧបសម្ព័ន្ធ “គ” និង “ឃ” របស់ IDP។ RTF នឹងត្រូវប្រើប្រាស់ដើម្បីប្រមូលព័ត៌មាន និងពិនិត្យអំពីវឌ្ឍនភាព នៃការអនុវត្តវិធានការគោលនយោបាយទាំង១២៣ របស់ IDP ពីក្រសួងស្ថាប័នទទួលខុសត្រូវនាំមុខ។ ព័ត៌មានចាំបាច់សម្រាប់វិធានការនីមួយៗនៅក្នុង RTF រួមមាន សូចនាករគោល (Milestone Indicators), ពេលវេលាបញ្ចប់, បញ្ហាប្រឈម និងសំណើដំណោះស្រាយ។ ក្នុងករណីចាំបាច់ សូចនាករបន្ថែម (Additional Progress Indicators) អាចនឹងត្រូវប្រើប្រាស់បន្ថែមលើសូចនាករគោលចំពោះវិធានការគោលនយោបាយមួយចំនួន។

### ២.៣. ការរៀបចំសូចនាករគន្លឹះ (Key Indicator) និងសូចនាករគោល (Milestone Indicator) សម្រាប់វាស់វែង

នៅក្នុងប្រព័ន្ធតាមដាន និងវាយតម្លៃនៃការអនុវត្ត IDP សូចនាករត្រូវបានរៀបចំឡើងជាបីកម្រិតដូចខាងក្រោម÷

១- សូចនាករកម្រិតយុទ្ធសាស្រ្តឬកម្រិតម៉ាក្រូ÷ សំដៅលើសូចនាករគន្លឹះ ដែលប្រើប្រាស់សម្រាប់វាស់វែងចក្ខុវិស័យ គោលបំណង និងគោលដៅ របស់ IDP។ សូចនាករកម្រិតយុទ្ធសាស្រ្តសរុបមានចំនួន ១៧ ដែលបានទទួលការឯកភាពក្នុងកិច្ចប្រជុំអន្តរក្រសួង ដូចមានក្នុងតារាងជូនភ្ជាប់។

២- សូចនាករកម្រិតវិស័យ ÷ សំដៅលើសូចនាករគន្លឹះ ដែលប្រើប្រាស់សម្រាប់វាយតម្លៃក្របខណ្ឌយុទ្ធសាស្ត្រ ឬអន្តរាគមន៍គោលនយោបាយទាំង ២០។ សូចនាករកម្រិតវិស័យសរុបមានចំនួន ៥៥ ដែលបានទទួលការឯកភាពក្នុងកិច្ចប្រជុំអន្តរក្រសួង ដូចមានក្នុងតារាងជូនភ្ជាប់។

៣- កម្រិតបច្ចេកទេសឬកម្រិតប្រតិបត្តិ÷ សំដៅលើសូចនាករគោល (Milestone Indicator) សម្រាប់ធ្វើការតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការគន្លឹះបួនជាក់ស្តែង (ម៉ាទ្រីស "គ") និងវិធានការ គោលនយោបាយនិងផែនការសកម្មភាព (ម៉ាទ្រីស "ឃ") របស់ IDP ទាំង១១៩។ វិធានការគោលនយោបាយនីមួយៗ មានសូចនាករគោលចំនួនបី ដែលនឹងត្រូវរៀបចំ តាមដាន និងរាយការណ៍ក្នុងកម្រិតបច្ចេកទេស។

សេចក្តីពន្យល់បន្ថែមអំពីហេតុផល និងវិធីសាស្ត្រក្នុងការរៀបចំសូចនាករគន្លឹះ (Key Indicator) និងសូចនាករគោល (Milestone Indicator) មានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធទី៤។

**តារាងទី២÷សូចនាករសម្រាប់តាមដាន និងវាយតម្លៃ**

| កម្រិត | ការរៀបចំក្នុងប្រព័ន្ធ M&E | ច្រវាក់លទ្ធផល | ចំនួនសូចនាករ |
|---|---|---|---|
| កម្រិតយុទ្ធសាស្ត្រ ឬកម្រិតម៉ាក្រូ | - គោលដៅអភិវឌ្ឍន៍ជាតិ (៣)<br>- ចក្ខុវិស័យ (១)<br>- គោលបំណង និងគោលដៅ (៥) | លទ្ធផលចុងក្រោយ ឬរយៈពេលវែង | ១៧ |
| កម្រិតវិស័យ | - អន្តរាគមន៍គោលនយោបាយ (២០) | លទ្ធផលបន្ទាប់ ឬរយៈពេលមធ្យម | ៥៥ |
| កម្រិតបច្ចេកទេស ឬកម្រិតប្រតិបត្តិ | - ឧបករណ៍គោលនយោបាយ (១២៣) | លទ្ធផលដំបូង ឬរយៈពេលខ្លី | ៣៦៩⁺ |

## ២.៤. ការប្រមូល និងគ្រប់គ្រងទិន្នន័យ

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (លេខាធិការដ្ឋាន IDP) មានកាតព្វកិច្ច ប្រមូល ធ្វើសុពលភាព និងគ្រប់គ្រងទិន្នន័យក្នុងប្រព័ន្ធតាមដាន និងវាយតម្លៃ។ ក្រសួង ស្ថាប័នពាក់ព័ន្ធមានកាតព្វកិច្ចផ្តល់ទិន្នន័យសម្រាប់ការតាមដាននិងវាយតម្លៃច្រវាក់លទ្ធផលទាំង ៣កម្រិត ។

## ២.៥. ការរៀបចំរបាយការណ៍ និងគណនេយ្យភាព

លេខាធិការដ្ឋាន IDP មានតួនាទីរៀបចំរបាយការណ៍ ៣ ប្រភេទ ដោយសហការ និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ÷

១. **របាយការណ៍តាមដានវឌ្ឍនភាពប្រចាំឆ្នាំ** នឹងត្រូវធ្វើឡើងដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្ត IDP ដោយផ្តោតលើសូចនាករទាំង ៣ កម្រិត និងត្រូវរាយការណ៍ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីប្រចាំឆ្នាំ។ ដោយឡែក ការតាមដានការអនុវត្តវិធានការគោលនយោបាយ និងផែនការសកម្មភាព ផ្តោតលើសូចនាករគោលកម្រិតបច្ចេកទេស ត្រូវរៀបចំដោយមានកិច្ចសហការរវាងលេខាធិការដ្ឋាន IDP និងមន្ត្រីបច្ចេកទេសរបស់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ និងរាយការណ៍ជូនថ្នាក់ដឹកនាំ ក.អ.ក. រៀងរាល់ឆមាស។

២. **របាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ** នឹងត្រូវរៀបចំឡើង ដើម្បីតាមដាន និងវាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្ត IDP ពីឆ្នាំ២០១៥ ដល់ដំណាច់ឆ្នាំ២០១៩។ របាយការណ៍នេះ នឹងគ្របដណ្តប់លើលទ្ធផលនៃការវាយតម្លៃសូចនាករទាំង ៣កម្រិត ដើម្បីពិនិត្យឡើងវិញពីយុទ្ធសាស្ត្រ អភិក្រម និងក្របខណ្ឌសម្រាប់ជាមូលដ្ឋាន ក្នុងការដាក់ចេញវិធានការកែតម្រូវ, អនុសាសន៍គោលនយោបាយ, វិធានការដោះស្រាយ, និងផែនការសកម្មភាពបន្ត។ របាយការណ៍នេះនឹងត្រូវបញ្ចប់នៅឆមាសទី១ ឆ្នាំ២០២១។

៣. **របាយការណ៍វាយតម្លៃចុងអាណត្តិ** នឹងត្រូវបានរៀបចំឡើងដោយផ្អែកលើការវាយតម្លៃសមិទ្ធផល និងបច្ច័យរយៈពេលវែងនៃការអនុវត្ត IDP ព្រមទាំងអាចដកស្រង់នូវបទពិសោធន៍ និងកំណត់ទិសដៅយុទ្ធសាស្ត្របន្តសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មនៅក្រោយឆ្នាំ២០២៥។

របាយការណ៍ទាំងនេះ គឺជាឯកសារផ្ទៃក្នុងរបស់រាជរដ្ឋាភិបាល ដែលនឹងត្រូវបោះពុម្ព និងចែកចាយជូនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដើម្បីចូលរួមតាមដានការងារ ដកពិសោធន៍នូវមេរៀនល្អៗ និងអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសបន្ទាប់ពីឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងទទួលបានការពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់ពី **សម្តេចមហាអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ផ្នែកខ្លះនៃរបាយការណ៍ អាចនឹងត្រូវពិនិត្យពិចារណា ក្នុងការបោះពុម្ពផ្សាយជាសាធារណៈ ដើម្បីឱ្យដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងគ្រប់ភាគីពាក់ព័ន្ធ ស្វែងយល់អំពីវឌ្ឍនភាពនៃការអនុវត្ត IDP និងផ្តល់ការគាំទ្រ ដើម្បីជំរុញការអភិវឌ្ឍន៍វិស័យឧស្សាហកម្មនៅកម្ពុជា ឱ្យកាន់តែមានជំនាញ ផលិតភាព តម្លៃបន្ថែម និងភាពប្រកួតប្រជែងខ្ពស់។

## ៣. បញ្ហាប្រឈម និងហានិភ័យ

ការអនុវត្តក្របខណ្ឌនេះ អាចជួបប្រទះបញ្ហាប្រឈមមួយចំនួន រួមមាន÷ (១) ពេលវេលា និងធនធាននៅមានកម្រិត ក្នុងការរៀបចំ ពិភាក្សា និងកំណត់សូចនាករពាក់ព័ន្ធ និងប្រភពទិន្នន័យ, (២) ការប្រមូល ចងក្រង វិភាគ បកស្រាយ និងសំយោគ តាមវិធីសាស្ត្រគុណវិស័យ និងបរិមាណវិស័យ ជាមួយនឹងការដាក់ចេញអនុសាសន៍គោលនយោបាយសម្រាប់ជាមូលដ្ឋានកំណត់វិធានការដោះស្រាយ និងផែនការសកម្មភាពបន្ត សម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ អាចទាមទារពេលវេលាច្រើន, (៣) ការវាយតម្លៃពាក់កណ្តាលអាណត្តិ

លើការអនុវត្ត IDP មានលក្ខណៈស្មុគស្មាញក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ខណៈដែលការសម្របសម្រួលយន្តការស្ថាប័នសម្រាប់អនុវត្តគោលនយោបាយនៅមានកម្រិត និងជួបប្រទះបញ្ហាថវិកា និងធនធានមនុស្ស និង (៤) ការវាយតម្លៃ និងការបកស្រាយសមិទ្ធកម្មអាចមានភាពលម្អៀង និងគម្លាតគ្នាច្រើន ដោយសារកង្វះសង្គតិភាពនៃទិន្នន័យ និង (៥) បញ្ហានៃការរីករាលដាលជំងឺកូវីដ-១៩ បាននិងកំពុងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្ត IDP ឱ្យបានទាន់ពេលវេលា។

ផ្អែកលើបញ្ហាប្រឈមខាងលើ ការរៀបចំសូចនាករគន្លឹះ និងសូចនាករគោល អាចនឹងត្រូវកែសម្រួលដោយមានកិច្ចសហការពីក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

## ៤. សេចក្តីសន្និដ្ឋាន

ក្របខណ្ឌតាមដាន និងវាយតម្លៃ នឹងដើរតួជាត្រីវិស័យក្នុងការរៀបចំ និងអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្ត IDP ដ៏ពេញលេញមួយ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានតម្លាភាព និងមានការចូលរួមពិគ្រោះយោបល់ពីគ្រប់តួអង្គពាក់ព័ន្ធ ដោយមានកំណត់នូវសូចនាករ និងគោលដៅថ្មីបន្ថែមទៀត ដែលអាចវាស់វែងបាន ហើយឆ្លើយតបទៅនឹងអាទិភាពនៃតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ ប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្ត IDP នេះ នឹងប្រើប្រាស់ឧបករណ៍ទាំង៣ គឺតក្កកម្មអន្តរាគមន៍ (Intervention Logic), ក្របខណ្ឌតក្កកម្ម (Log-frame), និងទម្រង់គំរូនៃរបាយការណ៍ (Report Template Format - RTF) ដោយកំណត់សូចនាករកម្រិតយុទ្ធសាស្ត្រ (ចំនួន ១៧), កម្រិតវិស័យ (ចំនួន ៥៥), និងកម្រិតបច្ចេកទេស (ចំនួន៣៦៩)។ សូចនាករទាំងអស់នេះ នឹងត្រូវរៀបចំសម្រាប់ការវាយតម្លៃពាក់កណ្តាលអាណត្តិ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩។ ដោយឡែក សូចនាករកម្រិតយុទ្ធសាស្ត្រ និងកម្រិតវិស័យ នឹងត្រូវកំណត់បន្ទាត់មូលដ្ឋាន គោលដៅ និងប្រភពទិន្នន័យ សម្រាប់ការតាមដានវឌ្ឍនភាពប្រចាំឆ្នាំ ចាប់ពីឆ្នាំ២០២១ និងការវាយតម្លៃចុងអាណត្តិ ដោយមានការពិភាក្សា និងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

ឧបសម្ព័ន្ធទី១÷ ដ្យាក្រាមសង្ខេបនៃក្របខណ្ឌការងារតាមដាន និងវាយតម្លៃការអនុវត្ត IDP



## ឧបសម្ព័ន្ធទី២÷ សេចក្តីពន្យល់បន្ថែមពីវិធីសាស្ត្រក្នុងការរៀបចំផ្នែកសំខាន់ៗទាំងបីនៃទ្រឹស្តីបរិវត្តកម្មរបស់ IDP ចូលទៅក្នុងរចនាសម្ព័ន្ធនៃប្រព័ន្ធតាមដាន និងវាយតម្លៃ

ការរៀបចំផ្នែកសំខាន់ៗទាំងបីនៃទ្រឹស្តីបរិវត្តកម្មរបស់ IDP ចូលទៅក្នុងរចនាសម្ព័ន្ធនៃប្រព័ន្ធតាមដាន និងវាយតម្លៃ ត្រូវបានធ្វើឡើងដោយ÷

- ផ្សារភ្ជាប់គោលនយោបាយ IDP ទៅនឹងគោលដៅអភិវឌ្ឍន៍ជាតិចម្បងចំនួន ៣ ដើម្បីពិនិត្យអំពីសង្គតិភាព និងការរួមចំណែករបស់គោលនយោបាយ IDP ក្នុងការសម្រេចបានចក្ខុវិស័យ និងអាទិភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។
- រៀបចំ និងសម្រួចគោលបំណងគោលនយោបាយ IDP ដែលមានចំនួន៣ ទៅជាគោលបំណងជាក់លាក់ (Explicit) ចំនួន៥ ដោយរំលេចបន្ថែមនូវគោលបំណងមិនជាក់លាក់ (Implicit) ដទៃទៀតដែលមានចែងនៅក្នុងគោលនយោបាយនេះ ដើម្បីឆ្លុះបញ្ចាំងឱ្យកាន់តែច្បាស់លាស់ពីលទ្ធផលចុងក្រោយក្នុងកម្រិតយុទ្ធសាស្ត្រ ដែលរាជរដ្ឋាភិបាលរំពឹងទុកពីការអនុវត្ត IDP និងស្របតាមការណែនាំរបស់ គ.ស.ហ. ដែលស្នើឱ្យពិនិត្យបន្ថែមគោលបំណងពាក់ព័ន្ធមួយចំនួនដូចជា ផលិតភាព និងការអភិវឌ្ឍជំនាញ។
- រៀបចំ និងសម្រួចក្របខណ្ឌយុទ្ធសាស្ត្រ ទៅជាអន្តរាគមន៍គោលនយោបាយ (Intervention Areas) ចំនួន ២០ ដែលមានភាពច្បាស់លាស់ និងអាចកំណត់សូចនាករ ដែលអាចវាស់វែងបាន។ បន្ទាប់មក ភ្ជាប់អន្តរាគមន៍គោលនយោបាយទាំង២០នេះ ទៅនឹងគោលបំណងគោលនយោបាយទាំង៥ខាងលើ។ អន្តរាគមន៍គោលនយោបាយទាំងនេះ សំដៅដល់លទ្ធផលជាក់លាក់រយៈពេលមធ្យមក្នុងកម្រិតវិស័យ ដែលរាជរដ្ឋាភិបាលរំពឹងថានឹងមានការផ្លាស់ប្តូរនៅពេលអនុវត្តវិធានការគោលនយោបាយរបស់ IDP។
- ផ្សារភ្ជាប់វិធានការគោលនយោបាយទាំង១២៣ (រួមទាំងវិធានការគន្លឹះបួនជាក់ស្តែង) ទៅនឹងអន្តរាគមន៍គោលនយោបាយទាំង២០ ខាងលើ។ វិធានការគោលនយោបាយ សំដៅដល់លទ្ធផលជាក់លាក់ដំបូង ឬរយៈពេលខ្លីក្នុងកម្រិតបច្ចេកទេស ដែលនឹងទទួលបានភ្លាមៗនៅពេលវិធានការទាំងនោះត្រូវបានអនុវត្ត និងសម្រេច។

**សម្គាល់÷** ការរៀបចំផ្នែកសំខាន់ៗនៃ IDP ចូលទៅក្នុងប្រព័ន្ធតាមដាននិងវាយតម្លៃនេះ មិនមែនជាការកែសម្រួលឯកសារគោលនយោបាយ IDP នោះទេ ប៉ុន្តែជាវិធីសាស្ត្រមួយនៅក្នុងប្រព័ន្ធតាមដាននិងវាយតម្លៃ សម្រាប់កំណត់ឱ្យបានគ្រប់ជ្រុងជ្រោយ ថាតើវឌ្ឍនភាព និងលទ្ធផលត្រង់កម្រិតណាខ្លះដែលនឹងត្រូវវាស់វែង និងវាយតម្លៃ។

ឧបសម្ព័ន្ធទី៣÷ តក្កកម្មអន្តរាគមន៍នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥



## ឧបសម្ព័ន្ធទី៤÷ សេចក្តីពន្យល់បន្ថែមពីការរៀបចំសូចនាករគន្លឹះ (Key Indicator) និងសូចនាករគោល (Milestone Indicator) សម្រាប់វាស់វែង

គោលនយោបាយ IDP បានដាក់ចេញនូវសូចនាករដែលមានចែងជាក់លាក់ (Explicit Indicator) ក្នុងកម្រិតយុទ្ធសាស្ត្រចំនួន ៣ គឺគោលដៅចម្បងទាំង៣ នៃ IDP។ ជាមួយគ្នានេះ គោលនយោបាយនេះ ក៏មានសូចនាករដែលមិនមានចែងជាក់លាក់ (Implicit Indicator) ជាច្រើន ដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រគន្លឹះទាំង៤ និងម៉ាទ្រីស "គ" និង "ឃ"។ សូចនាករទាំងនេះ នៅមិនទាន់គ្រប់គ្រាន់ និងឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវក្នុងការតាមដាន និងវាយតម្លៃដ៏មានប្រសិទ្ធភាពមួយនៅឡើយ។ ដូច្នេះ ប្រព័ន្ធតាមដាន និងវាយតម្លៃការអនុវត្ត IDP តម្រូវឱ្យមានការរៀបចំបន្ថែមនូវសូចនាករដែលអាចវាស់វែងបាន ដែលត្រូវបានបែងចែកជា ៣កម្រិត ដូចខាងក្រោម÷

១- **កម្រិតយុទ្ធសាស្ត្រ ឬកម្រិតម៉ាក្រូ**÷ សំដៅលើសូចនាករគោលដៅចម្បងទាំង៣ ដែលមានស្រាប់នៅក្នុងគោលនយោបាយ IDP សម្រាប់វាយតម្លៃកម្រិតម៉ាក្រូលើការសម្រេចបាននូវគោលបំណងដែលមានចែងជាក់លាក់ (Explicit Objectives) ទាំង៣ នៃគោលនយោបាយនេះ។ ប៉ុន្តែ ការប្រើប្រាស់ត្រឹមតែសូចនាករគោលដៅចម្បងទាំង៣ខាងលើនេះ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ ព្រោះវាមិនអាចឆ្លុះបញ្ចាំង ឬវាស់វែងអំពីកម្រិតនៃការសម្រេចនូវចក្ខុវិស័យ និងគោលបំណងដែលមិនមានចែងជាក់លាក់ (Implicit Objectives) របស់ IDP។ ក្នុងន័យនេះ សូចនាករគន្លឹះមួយចំនួនទៀត នឹងត្រូវបានរៀបចំបង្កើតឡើងសម្រាប់យកមកវាស់វែងក្នុងកម្រិតយុទ្ធសាស្ត្រនេះ ដោយគិតគូរបន្ថែមនូវសូចនាករពាក់ព័ន្ធទៅនឹងទំនាក់-ទំនងជាមួយផលិតភាព និងការអភិវឌ្ឍជំនាញជាដើម ដើម្បីឆ្លុះបញ្ចាំងអំពីការសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងដែលបានកំណត់ជាក់លាក់ ក៏ដូចជាគោលបំណងផ្សេងៗទៀត របស់ IDP សរុបចំនួន ៥។

២- **កម្រិតវិស័យ**÷ សំដៅលើសូចនាករគន្លឹះ ដែលត្រូវរៀបចំ និងប្រើប្រាស់សម្រាប់ការវាយតម្លៃលើការអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រ ដែលរួមមានមាន យុទ្ធសាស្ត្រគន្លឹះទាំង៤ (ការជំរុញការវិនិយោគ ការធ្វើទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម ការពង្រឹងបរិស្ថាននិយតកម្ម និងការសម្របសម្រួលគោលនយោបាយគាំទ្រ), វិសាលភាពនិងវិស័យអាទិភាព, និងអភិក្រមនៃការអនុវត្ត។ ក្របខណ្ឌយុទ្ធសាស្ត្រ នឹងត្រូវរៀបចំដាក់ក្នុងប្រព័ន្ធតាមដាននិងវាយតម្លៃ ជាទម្រង់អន្តរាគមន៍គោលនយោបាយ (Intervention Areas) ចំនួន២០។

៣- **កម្រិតបច្ចេកទេស ឬកម្រិតប្រតិបត្តិ**÷ សំដៅលើសូចនាករគោល (Milestone Indicators) សម្រាប់ធ្វើការតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការគន្លឹះបួនជាក់ស្តែង (ម៉ាទ្រីស "គ") ទិងវិធានការគោលនយោបាយ និងផែនការសកម្មភាព (ម៉ាទ្រីស "ឃ") របស់ IDP ទាំង១១៩ ដែលត្រូវធ្វើឡើងរៀងរាល់ ៦ខែម្តង តាមរយៈកិច្ចប្រជុំកម្រិតបច្ចេកទេសរវាងមន្ត្រីលេខាធិការដ្ឋាន IDP ជាមួយនឹងមន្ត្រីបច្ចេកទេសរបស់ក្រសួង ស្ថាប័ន

ទទួលខុសត្រូវនាំមុខ ក្នុងការអនុវត្ត IDP។ លេខាធិការដ្ឋាន IDP ត្រូវធ្វើរបាយការណ៍អំពីវឌ្ឍនភាពនេះ ជាទៀងទាត់ជូនថ្នាក់ដឹកនាំ ក.អ.ក.។

លទ្ធផលនៃការវាយតម្លៃសូចនាករកម្រិតយុទ្ធសាស្ត្រ និងកម្រិតវិស័យ នឹងត្រូវវាយការណ៍ជាកញ្ចប់ជូនប្រមុខរាជរដ្ឋាភិបាល ជារៀងរាល់ឆ្នាំ។ ការកំណត់សូចនាករគន្លឹះកម្រិតយុទ្ធសាស្ត្រ និងកម្រិតវិស័យ ដូចដែលមាននៅក្នុងក្របខណ្ឌតក្កកម្ម ត្រូវបានធ្វើឡើងតាមរយៈប្រជុំពិភាក្សា និងសម្រេចតែម្តងជាមួយក្រសួង ស្ថាប័នទទួលខុសត្រូវនាំមុខ និងស្ថាប័នផ្តល់ប្រភពទិន្នន័យផងដែរ។ ករណីមានការចាំបាច់ ឬការណែនាំពីថ្នាក់ដឹកនាំ ឬករណីកិច្ចប្រជុំជាមួយក្រសួង ស្ថាប័នទទួលខុសត្រូវនាំមុខមិនអាចសម្រេចបាន, ការកំណត់សូចនាករគន្លឹះកម្រិតយុទ្ធសាស្ត្រ និងកម្រិតវិស័យនេះ អាចនឹងត្រូវដាក់ជូន គ.ស.ហ. ពិនិត្យ និងសម្រេច។

ដោយឡែក ចំពោះសូចនាករគោលកម្រិតបច្ចេកទេស ដែលត្រូវកំណត់នៅក្នុង RTF នឹងត្រូវរៀបចំជា ៣ ដំណាក់កាល។ ដំណាក់កាលទី១ គឺជាការកំណត់សូចនាករគោលសម្រាប់វិធានការគោលនយោបាយនីមួយៗ និងសូចនាករបន្ថែមតាមការចាំបាច់សម្រាប់វិធានការគោលនយោបាយមួយចំនួន។ ដំណាក់កាលទី២ គឺជាការដាក់បញ្ចូលរួមគ្នានូវសូចនាករគោលទាំងអស់ដែលទទួលបានពីក្រសួង ស្ថាប័នទទួលខុសត្រូវនាំមុខ ចូលទៅក្នុង RTF តែមួយ។ ដំណាក់កាលទី៣ គឺជាការប្រមូលទិន្នន័យនិងព័ត៌មានអំពីវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ ទៅតាមសូចនាករគោល និងសូចនាករបន្ថែមដែលបានកំណត់នៅក្នុង RTF តាមរបបកំណត់ជាទៀងទាត់។ ក.អ.ក នឹងទទួលបន្ទុកសម្របសម្រួលដំណើរការនៃការរៀបចំប្រព័ន្ធនេះពីដើមដល់ចប់ ខណៈដែលក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវចូលរួមអនុវត្ត និងសហការក្នុងដំណាក់កាលទី១ និងទី៣។

វិធានការគោលនយោបាយនីមួយៗ ត្រូវមានសូចនាករគោល (Milestone Indicators) ចំនួន៣ សម្រាប់តាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការទាំងនោះ។ សូចនាករគោលទី១ បង្ហាញថាតើវិធានការគោលនយោបាយនោះត្រូវបានចាប់ផ្តើមអនុវត្តហើយឬនៅ។ សូចនាករគោលទី២ បង្ហាញថាតើវិធានការគោលនយោបាយនោះ មានវឌ្ឍនភាពកម្រិតណា បន្ទាប់ពីបានចាប់ផ្តើមអនុវត្ត។ សូចនាករគោលទី៣ បង្ហាញថាតើវិធានការគោលនយោបាយនោះ ត្រូវបានសម្រេចពេញលេញហើយឬនៅ។ រីឯសូចនាករបន្ថែម (Additional Progress Indicators) ដែលអាចនឹងត្រូវកំណត់បន្ថែមលើសូចនាករគោលចំពោះវិធានការគោលនយោបាយជាក់លាក់ណាមួយ គឺត្រូវបានប្រើប្រាស់ដើម្បីតាមដាននិងស្វែងយល់ឱ្យកាន់តែស៊ីជម្រៅលើវឌ្ឍនភាពនៃការអនុវត្តវិធានការនោះ ទាំងបែបគុណវិស័យ ទាំងបែបបរិមាណវិស័យ។

## សូចនាករគន្លឹះសម្រាប់ការតាមដាននិងវាយតម្លៃ

## ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥

| | ល.រ ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៩) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|
| *សូចនាករគន្លឹះកម្រិតយុទ្ធសាស្ត្រ* | | | | |
| **លទ្ធផលចុងក្រោយ ÷ គោលដៅអភិវឌ្ឍន៍ជាតិ** | កំណើនសេដ្ឋកិច្ចដែលមានភាពធន់នឹងវិបត្តិ | អត្រាកំណើន ផ.ស.ស ពិត | អត្រាកំណើន ផ.ស.ស ពិត គិតជា% | ក្រសួងផែនការ |
| | កំណើនការងារ | ចំនួនការងារផ្លូវការថ្មី ដែលបានចុះបញ្ជី | ចំនួនអ្នកទទួលបានការងារធ្វើផ្លូវការថ្មីនៅក្នុងវិស័យឯកជន (ចំនួនការងារក្នុងប្រទេស) ដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គិតជានាក់ | ក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ |
| | ការកាត់បន្ថយភាពក្រីក្រ | អត្រាភាពក្រីក្រ | អត្រាភាពក្រីក្រ គិតជា% | ក្រសួងផែនការ |
| **ចក្ខុវិស័យ** | ជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជាពីឧស្សាហកម្មអតិ-ពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ | ចំណែកនៃវិស័យឧស្សាហកម្មក្នុង ផ.ស.ស | ផលធៀបរវាង (១) តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្ម និង (២) ផ.ស.ស គិតជា% | ក្រសួងផែនការ |
| | | ចំណែកនៃវិស័យកម្មន្តសាលក្នុង ផ.ស.ស | ផលធៀបរវាង (១) តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល និង (២) ផ.ស.ស គិតជា% | ក្រសួងផែនការ |
| | | ចំណែកនៃការនាំចេញផលិតផលដែលប្រើបច្ចេកវិទ្យាមធ្យមនិងខ្ពស់ធៀបនឹងការនាំចេញទំនិញកម្មន្តសាលសរុប | ផលធៀបរវាង (១) ការនាំចេញផលិតផលដែលប្រើបច្ចេកវិទ្យាមធ្យមនិងខ្ពស់ និង (២) ការនាំចេញទំនិញកម្មន្តសាលសរុប គិតជា% | UNCOMTRADE/WITS |

| | ល.រ | ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៩) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|
| លទ្ធផល÷ គោលបំណងគោលនយោបាយឧស្សាហកម្ម | ១ | បង្កើនសកម្មភាពឧស្សាហកម្ម | តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្មសម្រាប់មនុស្សម្នាក់ | ផលធៀបរវាង (១) តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្ម និង (២) ចំនួនប្រជាជនសរុប គិតជាដុល្លារអាមេរិកក្នុងមនុស្សម្នាក់ | ក្រសួងផែនការ |
| | | | តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាលសម្រាប់មនុស្សម្នាក់ | ផលធៀបរវាង (១) តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល និង (២) ចំនួនប្រជាជនសរុប គិតជាដុល្លារអាមេរិកក្នុងមនុស្សម្នាក់ | ក្រសួងផែនការ |
| | ២ | បង្កើនការនាំចេញទំនិញឧស្សាហកម្ម និងកសិ-ឧស្សាហកម្ម | ការនាំចេញផលិតផលកម្មន្តសាលសម្រាប់មនុស្សម្នាក់ | ផលធៀបរវាង (១) ការនាំចេញផលិតផលកម្មន្តសាល និង (២) ចំនួនប្រជាជនសរុប គិតជាដុល្លារអាមេរិកក្នុងមនុស្សម្នាក់ | ក្រសួងផែនការ |
| | | | ចំណែកនៃការនាំចេញកសិផលកែច្នៃ ធៀបនឹងការនាំចេញសរុប | ផលធៀបរវាង (១) ការនាំចេញកសិផលកែច្នៃ និង (២) ការនាំចេញសរុប គិតជា% | ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ |
| | ៣ | សេដ្ឋកិច្ចដែលមានភាពធន់ និងមានពិពិធកម្ម | ចំណែកនៃតម្លៃបន្ថែមនៃអនុវិស័យកម្មន្តសាល ៣ នាំមុខគេ ធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល | ផលធៀបរវាង (១) តម្លៃបន្ថែមនៃអនុវិស័យកម្មន្តសាល ៣ នាំមុខគេ និង (២) តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល គិតជា% | ក្រសួងផែនការ |
| | | | ចំណែកនៃការនាំចេញផលិតផលកម្មន្ត-សាលមិនមែនសម្លៀកបំពាក់និងស្បែកជើង ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប | ផលធៀបរវាង (១) ការនាំចេញផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់និងស្បែកជើង និង (២) ការនាំចេញផលិតផលកម្មន្តសាលសរុប គិតជា% | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |

| | ល.រ | ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៩) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|
| | | | ចំណែកនៃការនាំចេញផលិតផលកសិ-ឧស្សាហកម្មកែច្នៃ ធៀបនឹងការនាំចេញផលិតផលកសិ-ឧស្សាហកម្មសរុប | ផលធៀបរវាង (១) ការនាំចេញផលិតផលកសិ-ឧស្សាហកម្មកែច្នៃ និង (២) ការនាំចេញផលិតផលកសិ-ឧស្សាហកម្មសរុប គិតជា% | ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ |
| | ៤ | ធ្វើឱ្យប្រសើរឡើងនូវគុណភាពការងារ | ចំនួនកម្មករក្នុងវិស័យកម្មន្តសាលមិនមែនសម្លៀកបំពាក់និងស្បែកជើង | ចំនួនកម្មករក្នុងវិស័យកម្មន្តសាលមិនមែនសម្លៀកបំពាក់និងស្បែកជើង ដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គិតជានាក់ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| | | | អត្រាអ្នកមានការងារធ្វើក្នុងវិស័យឧស្សាហកម្ម | ផលធៀបរវាង (១) ចំនួនការងារក្នុងវិស័យឧស្សាហកម្ម និង (២) ចំនួនការងារសរុប (អាយុ ១៥ឆ្នាំឡើង) គិតជា % | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| | ៥ | បង្កើនផលប្រយោជន៍ក្នុងស្រុកជាអតិបរមា | ជញ្ជីងពាណិជ្ជកម្មផលិតផលកម្មន្តសាល | ផលដករវាង (១) ការនាំចេញផលិតផលកម្មន្តសាល និង (២) ការនាំចូលផលិតផលកម្មន្តសាល គិតជាដុល្លារអាមេរិក | ក្រសួងផែនការ |
| | | | ចំណែកនៃការនាំចេញផលិតផលកសិ-ឧស្សាហកម្មកែច្នៃក្នុងស្រុក ធៀបនឹងការនាំចេញផលិតផលកសិ-ឧស្សាហកម្មសរុប | ផលធៀបរវាង (១) ការនាំចេញផលិតផលកសិ-ឧស្សាហកម្មកែច្នៃក្នុងស្រុក និង (២) ការនាំចេញផលិតផលកសិ-ឧស្សាហកម្មសរុប | ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ |
| *សូចនាករគន្លឹះកម្រិតវិស័យ* | | | | | |
| **លទ្ធផលបន្ទាប់÷អន្តរាគមន៍** | ១.១ | បង្កើនតម្រូវការក្នុងស្រុកនិងការជំនួស | ចំណែកនៃការនាំចូលផលិតផលកម្មន្តសាល ធៀបនឹងការប្រើប្រាស់ផលិតផលកម្មន្តសាលក្នុងស្រុកសរុប | ផលធៀបរវាង (១) ការនាំចូលផលិតផលកម្មន្តសាល និង (២) ការប្រើប្រាស់ផលិតផលកម្មន្តសាលក្នុងស្រុកសរុប គិតជា% | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ភាគយក) |

| | ល.រ | ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៩) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|
| គោលនយោបាយ | | ផលិតផលនាំចូល | | | ក្រសួងផែនការ (ភាគបែង) |
| | ១.២ | បង្កើនសកម្មភាពឧស្សាហកម្មថ្មីៗ | ចំនួនក្រុមហ៊ុន និងសហគ្រាសកម្មន្តសាលផ្លូវការថ្មីដែលបានចុះបញ្ជី | ចំនួនក្រុមហ៊ុន និងសហគ្រាសកម្មន្តសាលផ្លូវការថ្មីដែលបានចុះបញ្ជី | ក្រសួងពាណិជ្ជកម្ម |
| | | | ក្រុមផលិតផលកម្មន្តសាលថ្មីៗដែលបានផលិតនៅកម្ពុជា | ក្រុមផលិតផលកម្មន្តសាលថ្មីៗដែលបានផលិតនៅកម្ពុជា | ក្រសួងផែនការ |
| | ១.៣ | បង្កើនផលិតភាពការងាររបស់សហគ្រាស | ផលធៀបរវាងធាតុចេញផលិតកម្មសរុប និងចំនួនអ្នកចូលរួមការងារសរុបក្នុងវិស័យឧស្សាហកម្ម | ផលធៀបរវាង (១) ធាតុចេញផលិតកម្មសរុប និង (២) ចំនួនអ្នកចូលរួមការងារសរុបក្នុងវិស័យឧស្សាហកម្ម គិតជា ដុល្លារអាមេរិកក្នុងមនុស្សម្នាក់ | ក្រសួងផែនការ |
| | | | ផលធៀបរវាង តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្ម និងចំនួនអ្នកចូលរួមការងារសរុបក្នុងវិស័យឧស្សាហកម្ម | ផលធៀបរវាង (១) តម្លៃបន្ថែមសរុបនៃវិស័យឧស្សាហកម្ម និង (២) ចំនួនអ្នកចូលរួមការងារសរុបក្នុងវិស័យឧស្សាហកម្ម គិតជា ដុល្លារអាមេរិកក្នុងមនុស្សម្នាក់ | ក្រសួងផែនការ |
| | ១.៤ | បង្កើនកម្រិតបច្ចេកវិទ្យារបស់សហគ្រាស | ផលធៀបរវាងការនាំចូលផលិតផលមូលធន និងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល | ផលធៀបរវាង (១) ការនាំចូលផលិតផលមូលធន និង (២) តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល គិតជា% | ក្រសួងផែនការ |
| | ២.១ | បង្កើនការវិនិយោគក្នុង | ទុនវិនិយោគឯកជនក្នុងស្រុកក្នុងវិស័យឧស្សាហកម្ម | ទុនវិនិយោគឯកជនក្នុងស្រុកក្នុងវិស័យឧស្សាហកម្ម គិតជាដុល្លារអាមេរិក | ក្រសួងឧស្សាហកម្ម |

| ល.រ | ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៨) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|
| | វិស័យឧស្សាហកម្ម | | | វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| | | ទុនវិនិយោគផ្ទាល់ពីបរទេសនៅក្នុងវិស័យកម្មន្តសាល | ទុនវិនិយោគផ្ទាល់ពីបរទេសនៅក្នុងវិស័យកម្មន្តសាល គិតជាដុល្លារអាមេរិក | ធនាគារជាតិនៃកម្ពុជា |
| | | ទុនវិនិយោគក្នុងវិស័យកម្មន្តសាល ធៀបនឹងការវិនិយោគសរុប | ផលធៀបរវាង (១) ទុនវិនិយោគក្នុងវិស័យកម្មន្តសាល (Mfg. GFCF) និង (២) ទុនវិនិយោគសរុប (Total GFCF) គិតជា% | ក្រសួងផែនការ |
| ២.២ | ពង្រីកនិងធ្វើពិពិធកម្មទីផ្សារ និងផលិតផលនាំចេញ | ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលទៅទីផ្សារសំខាន់ ៣ នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប | ផលធៀបរវាង (១) ការនាំចេញផលិតផលកម្មន្តសាលទៅទីផ្សារសំខាន់ ៣នាំមុខគេ និង (២) ការនាំចេញផលិតផលកម្មន្តសាលសរុប គិតជា% | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |
| | | ចំនួនទីផ្សារនាំចេញ (ការនាំចេញខ្ពស់ជាងកម្រិតណាមួយ ឧ÷ ១០លានដុល្លារអាមេរិក) | ចំនួនទីផ្សារនាំចេញ (ការនាំចេញខ្ពស់ជាងកម្រិតណាមួយ ឧ÷ ១០លានដុល្លារអាមេរិក) គិតជាប្រទេស/តំបន់ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |
| | | ចំណែកនៃការនាំចេញផលិតផលកម្មន្តសាលសំខាន់ ៥ នាំមុខគេ ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប | ផលធៀបរវាង (១) ការនាំចេញផលិតផលកម្មន្តសាល ៥ នាំមុខគេ និង (២) ការនាំចេញផលិតផលកម្មន្តសាលសរុប គិតជា% | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |

| | ល.រ | ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៩) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|
| | ២.៣ | ការតភ្ជាប់រវាងសហគ្រាសក្នុងស្រុក ជាមួយសហគ្រាសបរទេស (រួមទាំងការផ្ទេរបច្ចេកវិទ្យា) | ចំនួនសហគ្រាសក្នុងស្រុកដែលផ្គត់ផ្គង់ធាតុចូលផលិតកម្មសម្រាប់សហគ្រាសបរទេស | ចំនួនសហគ្រាសក្នុងស្រុកដែលផ្គត់ផ្គង់ធាតុចូលផលិតកម្មសម្រាប់សហគ្រាសបរទេស គិតជាចំនួនសហគ្រាស | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| | ២.៤ | ធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងការតភ្ជាប់ | បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវគោក | បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវគោក (តាមមាត់ច្រកសំខាន់ពីរគឺ បាវិត និងប៉ោយប៉ែត) គិតជាតោន | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| | | | ចំនួនច្រកទ្វារព្រំដែនដែលបានបង្កើត និងដាក់ឱ្យដំណើរការជាផ្លូវការ | ចំនួនច្រកទ្វារព្រំដែនដែលបានបង្កើត និងដាក់ឱ្យដំណើរការជាផ្លូវការ | ក្រសួងមហាផ្ទៃ |
| | | | ចំនួនច្រកទ្វារព្រំដែនដែលបានដំឡើងកម្រិតសមត្ថភាពឱ្យមានភាពស្មើគ្នាជាមួយប្រទេសជិតខាង | ចំនួនច្រកទ្វារព្រំដែនដែលបានដំឡើងកម្រិតសមត្ថភាពឱ្យមានភាពស្មើគ្នាជាមួយប្រទេសជិតខាង | ក្រសួងមហាផ្ទៃ |
| | | | បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវដែក | បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវដែក គិតជាតោន | ក្រសួងសាធារណការ និងដឹកជញ្ជូន |
| | | | បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់កំពង់ផែ | បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់កំពង់ផែ គិតជាតោន | ក្រសួងសាធារណការ និងដឹកជញ្ជូន |

| ល.រ | ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៩) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|
| | | | | |
| | | បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវអាកាស | បរិមាណទំនិញដឹកជញ្ជូនឆ្លងកាត់ផ្លូវអាកាស គិតជាតោន | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល |
| | | អត្រាអ្នកប្រើប្រាស់អ៊ីនធឺណិតល្បឿនលឿន | អត្រាអ្នកប្រើប្រាស់អ៊ីនធឺណិតល្បឿនលឿន ក្នុងចំណោមប្រជាជន១០០នាក់ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | វិសាលភាពគ្របដណ្ដប់នៃសេវាអ៊ីនធឺណិតល្បឿនលឿន នៅតំបន់ដែលមានប្រជាជនរស់នៅ | វិសាលភាពគ្របដណ្ដប់នៃសេវាអ៊ីនធឺណិតល្បឿនលឿន នៅតំបន់ដែលមានប្រជាជនរស់នៅ គិតជា% | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| | | សន្ទស្សន៍នៃភូមិដែលទទួលបានការផ្គត់ផ្គង់អគ្គិសនី | ផលធៀបរវាង (១) ចំនួនភូមិទទួលបានការផ្គត់ផ្គង់អគ្គិសនី និង (២) ចំនួនភូមិសរុបទូទាំងប្រទេស គិតជា% | ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា |
| | | ថ្លៃអគ្គិសនីសម្រាប់ការប្រើប្រាស់ក្នុងឧស្សាហកម្ម | តម្លៃអគ្គិសនីសម្រាប់ការប្រើប្រាស់ក្នុងឧស្សាហកម្ម គិតជាសេនដុល្លារអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការផ្គត់ផ្គង់ពីខ្សែតង់ស្យុងមធ្យម (MV) | ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា |
| | | ស្ថិរភាពនៃការផ្គត់ផ្គង់ថាមពល | ចំនួនដង ឬរយៈពេលនៃការដាច់ចរន្តអគ្គិសនី | ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា |
| ៣.១ | បង្កើនសមត្ថភាពនាំចេញរបស់ | ចំណែកនៃចំនួនសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាលដែលធ្វើការនាំចេញ | ផលធៀបរវាង (១) ចំនួនសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាលដែលធ្វើការនាំចេញ និង (២) ចំនួនសហគ្រាសធុនតូចនិងមធ្យមក្នុង | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |

| ល.រ | ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៩) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|
| | ក្រុមហ៊ុន/សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក | ធៀបនឹងចំនួនសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាលសរុប | វិស័យកម្មន្តសាលសរុប គិតជា% | |
| | | ចំណែកនៃការនាំចេញរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាល ធៀបនឹងការនាំចេញសរុប | ផលធៀបរវាង (១) ការនាំចេញរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យកម្មន្តសាល និង (២) ការនាំចេញសរុប គិតជា% | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ភាគយក) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ភាគបែង) |
| ៣.២ | ធ្វើឱ្យមានតុល្យភាពរវាងសហគ្រាសធុនធំ និងសហគ្រាសធុនតូចនិងមធ្យម | ចំណែកនៃតម្លៃបន្ថែមផលិតកម្មកម្មន្តសាលនៃសហគ្រាសធុនតូចនិងមធ្យម ធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល | ផលធៀបរវាង (១) តម្លៃបន្ថែមផលិតកម្មកម្មន្តសាលនៃសហគ្រាសធុនតូចនិងមធ្យម និង (២) តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល គិតជា% | ក្រសួងផែនការ |
| | | ចំណែកនៃចំនួនការងារដែលផ្តល់ដោយសហគ្រាសធុនតូចនិងមធ្យម ធៀបនឹងចំនួនការងារសរុបក្នុងវិស័យឧស្សាហកម្ម | ផលធៀបរវាង (១) ចំនួនការងារដែលផ្តល់ដោយសហគ្រាសធុនតូចនិងមធ្យម ដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (មានកម្មករនិយោជិតពី ១-១០០នាក់) និង (២) ចំនួនការងារសរុបក្នុងវិស័យឧស្សាហកម្ម គិតជា% | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ៣.៣ | នវានុវត្តន៍ផ្នែកឧស្សាហកម្ម | ចំនួនប្រកាសនីយបត្រតក្កកម្មជាធរមាន | ចំនួនប្រកាសនីយបត្រតក្កកម្មជាធរមាន គិតជាស្តុក | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |

| ល.រ | ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៩) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|
| | | ចំនួនប្រកាសនីយបត្រតក្កកម្មដែលផ្តល់ជូននិវាសនជន ធៀបនឹងចំនួនសំណើនៃការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មរបស់និវាសនជន | ផលធៀបរវាង (១) ចំនួនប្រកាសនីយបត្រតក្កកម្មដែលផ្តល់ជូននិវាសនជន និង (២) ចំនួនសំណើនៃការដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មរបស់និវាសនជន គិតជា% | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| ៣.៤ | ទំនើបកម្មសហគ្រាសធុនតូច និងមធ្យម | អត្រាចុះបញ្ជីរបស់សហគ្រាសធុនធំ | ផលធៀបរវាង (១) ចំនួនសហគ្រាសធុនធំសរុបដែលបានចុះបញ្ជី និង (២) ចំនួនសហគ្រាសធុនធំសរុបទូទាំងប្រទេស (ទាំងចុះបញ្ជី និងមិនបានចុះបញ្ជី) | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | អត្រាចុះបញ្ជីរបស់សហគ្រាសធុនមធ្យម | ផលធៀបរវាង (១) ចំនួនសហគ្រាសធុនមធ្យមសរុបដែលបានចុះបញ្ជី និង (២) ចំនួនសហគ្រាសធុនមធ្យមសរុបទូទាំងប្រទេស (ទាំងចុះបញ្ជី និងមិនបានចុះបញ្ជី) គិតជា% | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| | | អត្រាចុះបញ្ជីរបស់សហគ្រាសធុនតូច | ផលធៀបរវាង (១) ចំនួនសហគ្រាសធុនតូចសរុបដែលបានចុះបញ្ជី និង (២) ចំនួនសហគ្រាសធុនតូចសរុបទូទាំងប្រទេស (ទាំងចុះបញ្ជី និងមិនបានចុះបញ្ជី) គិតជា% | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

| | ល.រ | ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៩) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|
| | | | អត្រាសហគ្រាសធុនធំដែលមានតារាងតុល្យការ | ផលធៀបរវាង (១) ចំនួនសហគ្រាសធុនធំសរុបដែលមានតារាងតុល្យការ និង (២) ចំនួនសហគ្រាសធុនធំសរុបទូទាំងប្រទេស (ទាំងមាន និងមិនមានតារាងតុល្យការ) គិតជា% | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ អគ្គនាយកដ្ឋានពន្ធដារ |
| | | | អត្រាសហគ្រាសធុនមធ្យមដែលមានតារាងតុល្យការ | ផលធៀបរវាង (១) ចំនួនសហគ្រាសធុនមធ្យមសរុបដែលមានតារាងតុល្យការ និង (២) ចំនួនសហគ្រាសធុនមធ្យមសរុបទូទាំងប្រទេស (ទាំងមាន និងមិនមានតារាងតុល្យការ) គិតជា% | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ អគ្គនាយកដ្ឋានពន្ធដារ |
| | | | អត្រាសហគ្រាសធុនតូចដែលមានតារាងតុល្យការ | ផលធៀបរវាង (១) ចំនួនសហគ្រាសធុនតូចសរុបដែលមានតារាងតុល្យការ និង (២) ចំនួនសហគ្រាសធុនតូចសរុបទូទាំងប្រទេស (ទាំងមាន និងមិនមានតារាងតុល្យការ) គិតជា% | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ អគ្គនាយកដ្ឋានពន្ធដារ |
| | ៤.១ | ធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍជំនាញ និងធនធានមនុស្ស | ចំណែកនៃការចុះឈ្មោះចូលរៀននៅមធ្យមសិក្សា និងឧត្តមសិក្សាក្នុងចំនួនប្រជាជនសរុប | ផលធៀបរវាង (១) ចំនួនសរុបនៃការចុះឈ្មោះចូលរៀននៅមធ្យមសិក្សានិងឧត្តមសិក្សា និង (២) ចំនួនប្រជាជនសរុប គិតជា% | ក្រសួងអប់រំ យុវជន និងកីឡា |
| | | | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | ផលធៀបរវាង (១) ចំនួនសិស្សថ្មី (មិនរាប់សិស្សរៀនត្រួតថ្នាក់) រៀនថ្នាក់ទី១២ ក្នុងឆ្នាំសិក្សា (T) និង (២) ចំនួនប្រជាជនសរុបដែលមានអាយុ ១៧ឆ្នាំក្នុងឆ្នាំសិក្សា (T) គិតជា% | ក្រសួងអប់រំ យុវជន និងកីឡា |

| ល.រ | ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៩) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|
| | | ចំនួនសិស្សបញ្ចប់ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១ ២ ឬ ៣ (C1, C2 ឬ C3) | ចំនួនសិស្សបញ្ចប់ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដែលមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ១ ២ ឬ ៣ (C1, C2 ឬ C3) គិតជានាក់ | ក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ |
| | | ចំនួននិស្សិតបញ្ចប់ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដែលមានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស/បរិញ្ញាបត្ររងនិងវិស្វករ | ចំនួននិស្សិតបញ្ចប់ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដែលមានសញ្ញាបត្រ ជាន់ខ្ពស់បច្ចេកទេស/ឯកទេស/បរិញ្ញាបត្ររងនិងវិស្វករ គិតជានាក់ | ក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ |
| | | អត្រានិស្សិតបញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា | ផលធៀបរវាង (១) ចំនួននិស្សិតសរុបផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា និង (២) ចំនួននិស្សិតសរុបបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សា គិតជា% | ក្រសួងអប់រំ យុវជន និងកីឡា |
| ៤.២ | តម្រូវការពលកម្មជំនាញ | ចំនួនព័ត៌មានតម្រូវការជ្រើសរើសកម្លាំងពលកម្មជំនាញ | ចំនួនព័ត៌មានតម្រូវការជ្រើសរើសកម្លាំងពលកម្មជំនាញដែលប្រមូល និងផ្សព្វផ្សាយដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមប្រភេទនៃមុខរបរ គិតជានាក់ | ក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ |
| | | ចំនួនកម្លាំងពលកម្មជំនាញ | ចំនួនកម្លាំងពលកម្មជំនាញសរុប (អ្នកដែលទទួលបានការអប់រំ និងការបណ្តុះបណ្តាលយ៉ាងតិច ឬស្មើកម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬអ្នកដែលទទួលបានការអប់រំបណ្តុះបណ្តាល | ក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ |

| ល.រ | ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៩) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|
| | | | បច្ចេកទេស និងវិជ្ជាជីវៈ យ៉ាងតិចឬស្មើសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១ (C1)) គិតជានាក់ | |
| ៤.៣ | ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ | ជានាយន្តការត្រីភាគីក្នុងការចរចាប្រាក់ឈ្នួលអប្បបរមាដោយផ្អែកលើលក្ខណវិនិច្ឆ័យបែបសង្គមនិងសេដ្ឋកិច្ចដែលបានចែងក្នុងច្បាប់ស្ដីពីប្រាក់ឈ្នួលអប្បបរមា | ប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់ជាប្រចាំឆ្នាំតាមយន្តការត្រីភាគី និងផ្អែកលើលក្ខណវិនិច្ឆ័យបែបសង្គម និងសេដ្ឋកិច្ច គិតជាដុល្លារអាមេរិក | ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ |
| | | ភាគរយនៃវិវាទការងារ (ធំៗ) ដែលបានដោះស្រាយ | ផលធៀបរវាង (១) ចំនួនវិវាទការងារដែលត្រូវបានដោះស្រាយសះជា (ទាំងកម្រិតមន្ត្រីផ្សះផ្សា និងក្រុមប្រឹក្សាអាជ្ញាកណ្ដាល) និង (២) ចំនួនវិវាទការងារសរុប គិតជា% | ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ |
| ៤.៤ | ការផ្គូផ្គងការងារ | អត្រាសហគ្រាសក្នុងស្រុកដែលជួបប្រទះបញ្ហាគម្លាតជំនាញ | ផលធៀបរវាង (១) ចំនួនសហគ្រាសដែលជួបប្រទះបញ្ហាគម្លាតជំនាញ និង (២) ចំនួនសហគ្រាសសរុប គិតជា% | ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ |
| | | ចំណែកនៃសហគ្រាសរាយការណ៍ដែលមានស្ថានភាពលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្ម ក្នុងចំនួនសហគ្រាសសរុបដែលមានតម្រូវការជ្រើសរើសកម្លាំងពលកម្ម យ៉ាងតិចមួយ | ផលធៀបរវាង (១) ចំនួនសហគ្រាសរាយការណ៍ដែលមានស្ថានភាពលំបាកក្នុងការជ្រើសរើសកម្លាំងពលកម្ម និង (២) ចំនួនសហគ្រាសសរុបដែលមានតម្រូវការជ្រើសរើសពលកម្ម យ៉ាងតិចមួយ គិតជា% | ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ |

| ល.រ | ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៩) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|
| ៤.៥ | ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ | អត្រាសហគ្រាស គ្រឹះស្ថាន ដែលមានសេវាសង្គ្រោះអប្បបរមា | ផលធៀបរវាង (១) ចំនួនសហគ្រាសគ្រឹះស្ថានដែលចុះបញ្ជីនៅក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលមានសេវាសង្គ្រោះអប្បបរមា និង (២) ចំនួនសហគ្រាសគ្រឹះស្ថានសរុបដែលចុះបញ្ជីនៅក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ គិតជា% | ក្រសួងការងារ និងបណ្ដុះ-បណ្ដាលវិជ្ជាជីវៈ |
| | | ចំនួនកម្មករដែលទទួលបានបណ្ណសមាជិក ប.ស.ស | ចំនួនកម្មករដែលទទួលបានបណ្ណសមាជិក ប.ស.ស គិតជានាក់ | ក្រសួងការងារ និងបណ្ដុះ-បណ្ដាលវិជ្ជាជីវៈ |
| ៥.១ | ពង្រីកខ្សែចង្វាក់តម្លៃក្នុងស្រុក | ចំណែកនៃតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល ធៀបនឹងការនាំចេញផលិតផលកម្មន្តសាលសរុប | ផលធៀបរវាង (១) តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល និង (២) ការនាំចេញផលិតផលកម្មន្តសាលសរុប គិតជា% | ក្រសួងផែនការ (ភាគយក)<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ភាគបែង) |
| ៥.២ | បង្កើនភាពជាម្ចាស់របស់ក្រុមហ៊ុន និងសហគ្រាសក្នុងស្រុក | ចំនួនក្រុមហ៊ុន និងសហគ្រាសដែលមានម្ចាស់ភាគហ៊ុនខ្មែរកាន់កាប់ចាប់ពី ៥១% ឡើងទៅ | ចំនួនក្រុមហ៊ុន និងសហគ្រាសក្នុងស្រុកដែលមានម្ចាស់ភាគហ៊ុនខ្មែរកាន់កាប់ចាប់ពី ៥១% ឡើងទៅ | ក្រសួងពាណិជ្ជកម្ម |
| | | ចំណែកនៃតម្លៃបន្ថែមនៃវិស័យកម្មន្តសាលដែលបានបង្កើតដោយសហគ្រាសបរទេស ធៀបនឹងតម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល | ផលធៀបរវាង (១) តម្លៃបន្ថែមនៃវិស័យកម្មន្តសាលដែលបានបង្កើតដោយសហគ្រាសបរទេស និង (២) តម្លៃបន្ថែមសរុបនៃវិស័យកម្មន្តសាល គិតជា% | ក្រសួងផែនការ |

| ល.រ | ពណ៌នា | សូចនាករ (ឆ្នាំ២០០៥-២០១៩) | ពណ៌នាសូចនាករ | ប្រភពទិន្នន័យ |
|---|---|---|---|---|
| | | ចំណែកនៃចំនួនការងារសរុបដែលបានបង្កើតដោយសហគ្រាសបរទេស ធៀបនឹងចំនួនការងារសរុប | ផលធៀបរវាង (១) ចំនួនការងារសរុបដែលបានបង្កើតដោយសហគ្រាសបរទេសដែលចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង (២) ចំនួនការងារសរុប គិតជា% | ក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ |
| ៥.៣ | បង្កើនការកែច្នៃផលិតផលកសិកម្មសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញ | ចំណែកនៃទុនវិនិយោគក្នុងផលិតកម្មកសិ-ឧស្សាហកម្ម ធៀបនឹងទុនវិនិយោគសរុប | ផលធៀបរវាង (១) ទុនវិនិយោគសរុបក្នុងផលិតកម្មកសិ-ឧស្សាហកម្ម និង (២) ទុនវិនិយោគសរុប គិតជា% | ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ (ភាគយក)<br>ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ភាគបែង សម្រាប់តែ QIP)<br>ធនាគារជាតិនៃកម្ពុជា (ភាគបែង) |
| | | ការនាំចេញនៃកសិផលកែច្នៃពាក់កណ្តាលសម្រេច និងសម្រេច | ការនាំចេញនៃកសិផលកែច្នៃពាក់កណ្តាលសម្រេចនិងសម្រេច គិតជាដុល្លារអាមេរិក | ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៧៥០ សហវ.គសហ

ខុទ្ទកាល័យសម្តេចតេជោ (វិមានសន្តិភាព)
ចូល
លេខ 126 ខុ.ម
ថ្ងៃទី 12.03.2020
ម៉ោង 5:00 PM

*ថ្ងៃ៣រោច ខែផល្គុន ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២០*

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** របាយការណ៍កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការពិនិត្យលើ "សេចក្តីព្រាងវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (IDP) ក្នុងឆ្នាំ ២០១៧-២០១៨" ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ នាព្រឹកថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២០, ខ្ញុំបានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការគោល-នយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គសហ) ដើម្បីពិនិត្យ និងពិភាក្សាលើ "សេចក្តីព្រាងវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (IDP) ក្នុងឆ្នាំ ២០១៧-២០១៨"។ កិច្ចប្រជុំនេះបានការអញ្ជើញចូលរួមពី ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ឯកឧត្តម **ជិន ប៊ុនស៊ាន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានក្រុម-ប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, ឯកឧត្តមនាយឧត្តមសេនីយ៍បណ្ឌិត **ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល, ឯកឧត្តម **សុខ ចិន្តាសោភា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ឯកឧត្តម **ឈៀង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការគណៈកម្មាធិការនីតិ-សម្បទា និងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ព្រមទាំងថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័នពាក់ព័ន្ធជាច្រើនរូបទៀត។ ក្នុងន័យនេះ ខ្ញុំសូមគោរពរាយការណ៍ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** នូវលទ្ធផលសំខាន់ៗនៃកិច្ចប្រជុំ ដូចខាងក្រោម៖

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **ជិន ប៊ុនស៊ាន** បានធ្វើរបាយការណ៍ជូនអង្គប្រជុំពីសាវតារនៃការរៀបចំសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត IDP ក្នុង ឆ្នាំ ២០១៧-២០១៨, រួចហើយតំណាងលេខាធិ-ការដ្ឋានដឹកនាំនិងសម្របសម្រួលការអនុវត្ត IDP បានធ្វើបទបង្ហាញសង្ខេបលើសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពដោយគូសរំលេចនូវគោលដៅចម្បង ០៣ និង វិធានការគន្លឹះ ០៤ ដែលជារួមមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ខណៈ ផ្នែកខ្លះនៃវិធានការមានវឌ្ឍនភាពយឺត ឬសម្រេចបានដោយផ្នែក។ បន្ទាប់ពីបានពិភាក្សាយ៉ាងផុសផុល និងល្អិតល្អន់, ជារួម អង្គប្រជុំបានវាយតម្លៃខ្ពស់លើការរៀបចំសេចក្តីព្រាងវឌ្ឍនភាពនេះ និងបាន

ឯកភាពលើទម្រង់ និងខ្លឹមសារនៃរបាយការណ៍ដែលបានរៀបចំឡើងដោយលេខាធិការដ្ឋានដឹកនាំនិងសម្របសម្រួលការអនុវត្ត IDP។ ទន្ទឹមនេះ អង្គប្រជុំបានស្នើឱ្យពិនិត្យនិងកែសម្រួលលើចំណុចមួយចំនួន ដូចខាងក្រោម៖

- ផ្ទៀងផ្ទាត់ឡើងវិញនូវប្រភព និងសុក្រឹតភាពនៃទិន្នន័យ សម្រាប់សូចនាករគោលដៅចម្បងទាំង ០៣, និង
- ធ្វើបច្ចុប្បន្នកម្មវឌ្ឍនភាពនៃវិធានការគន្លឹះទាំង ០៤ ដោយពិភាក្សា និងផ្ទៀងផ្ទាត់ជាមួយក្រសួង-ស្ថាប័ននាំមុខអនុវត្ត និង ដោយបែងចែកលទ្ធផលជា ៤ កម្រិតគឺ ១). គ្មានវឌ្ឍនភាព ឬយឺតខ្លាំង, ២). សម្រេចបានដោយផ្នែក, ៣). សម្រេចបានភាគច្រើន និង៤). សម្រេចបានពេលលេញ។ ចំពោះវិធានការដែលអនុវត្តបានត្រឹមកម្រិត ទី២ ទី៣ និង ទី៤ ត្រូវបញ្ជាក់អំពីលទ្ធផលដែលសម្រេចបានជាក់លាក់ បញ្ហាប្រឈម កិច្ចការដែលត្រូវធ្វើបន្ត និងពេលវេលាបញ្ចប់។

ជាមួយគ្នានេះ អង្គប្រជុំក៏បានឯកភាពថា បន្ទាប់ពីទទួលបានការកែសម្រួល និងសម្អាតរួច ស្នើសុំសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្ត (IDP) ក្នុងឆ្នាំ ២០១៧-២០១៨ ដាក់ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដើម្បីសុំការសម្រេចជាចុងក្រោយ ដោយមិនចាំបាច់ឆ្លងកិច្ចប្រជុំ គ.ស.ហ ជាលើកទី ២ នោះទេ។ លើសពីនេះ អង្គប្រជុំបានពិភាក្សាពីការត្រៀមក្នុងការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ (Mid-Term Review) ដែលនឹងត្រូវធ្វើឡើងក្នុងឆមាសទី ១ ឆ្នាំ ២០២១។ ក្នុងនោះ អង្គប្រជុំបានផ្តល់ការណែនាំដូចខាងក្រោម៖

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបន្តតួនាទីដឹកនាំ, សម្របសម្រួល និងរៀបចំក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្ត IDP (M&E Framework) ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ,
- ក្របខណ្ឌនេះ គួរយកលំនាំតាមការរៀបចំក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្ត យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ដោយកំណត់សូចនាករគន្លឹះ ៣ កម្រិត រួមមាន៖
    - **កម្រិតយុទ្ធសាស្ត្រ៖** ផ្តោតលើសូចនាករគោលដៅចម្បងទាំង ៣ ប៉ុន្តែមានគិតគូរលើសូចនាករបន្ថែម ឬកែសម្រួលខ្លះ និងជាពិសេស រំលេចឱ្យឃើញពីទំនាក់ទំនងជាមួយ ផលិតភាព និងការ-អភិវឌ្ឍជំនាញ។ លទ្ធផលនៃការវាយតម្លៃសូចនាករកម្រិតយុទ្ធសាស្ត្រនេះនឹងត្រូវរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ជារៀងរាល់ឆ្នាំ,
    - **កម្រិតវិស័យ៖** ផ្តោតលើសូចនាករវិធានការគោលនយោបាយ និងផែនការសកម្មភាព ដោយផ្អែកលើវិធានការគន្លឹះ ៤ គឺ ១). ការជំរុញការទាក់ទាញវិនិយោគ, ២). ការពង្រីក និងទំនើប-កម្មសហគ្រាសធុនតូច និងមធ្យម, ៣). ការកែលម្អបរិស្ថាននិយ័តកម្ម និង ៤). ការសម្រប-សម្រួលគោលនយោបាយគាំទ្រ។ សូចនាករកម្រិតវិស័យនេះត្រូវកំណត់ឱ្យបានច្បាស់នូវស្ថាប័នដឹកនាំ, ហើយក្រសួង-ស្ថាប័នទទួលបន្ទុកត្រូវវាយតម្លៃនូវវឌ្ឍនភាព និងរាយការណ៍ប្រចាំឆមាស ទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា,
    - **កម្រិតបច្ចេកទេស៖** ជាសូចនាករលម្អិតដែលនឹងជួយសម្រួលដល់ក្រុមការងារបច្ចេកទេស និងលេខាធិការដ្ឋានក្នុងការតាមដានវឌ្ឍនភាពនៃផែនការសកម្មភាព និងជាធាតុចូលសម្រាប់ការរាយការណ៍សូចនាករកម្រិតយុទ្ធសាស្ត្រ និងកម្រិតវិស័យ។ ក្រុមការងារបច្ចេកទេសដែល

ទទួលបន្ទុក ត្រូវពិនិត្យនិងតាមដានការអនុវត្ត សូចនាករកម្រិតបច្ចេកទេសនេះ ហើយត្រូវរាយការណ៍ប្រចាំត្រីមាសក្នុងកិច្ចប្រជុំកម្រិតលេខាធិការដ្ឋាន។

- ការវាយតម្លៃពាក់កណ្តាលអាណត្តិត្រូវមាន ៤ កម្រិតដែរ គឺ ១). គ្មានវឌ្ឍនភាព ឬយឺតខ្លាំង, ២). សម្រេចបានដោយផ្នែក, ៣). សម្រេចបានភាគច្រើន និង ៤). សម្រេចបានពេញលេញ,
- ពិនិត្យឡើងវិញលើភាពពាក់ព័ន្ធ (relevance) នៃសូចនាករគន្លឹះ ក្នុងន័យបន្ថែម ឬកែសម្រួល រួមទាំងធ្វើបច្ចុប្បន្នកម្ម គោលដៅ យុទ្ធសាស្ត្រ គោលនយោបាយ និង ផែនការសកម្មភាពសម្រាប់អនុវត្ត IDP ដើម្បីឱ្យឆ្លុះបញ្ចាំងពីបរិការណ៍នៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមក្នុងតំបន់និងប្រទេស។ សម្រាប់វិធាន ការដែលមានវឌ្ឍនភាពតិចតួច ត្រូវមានការកំណត់បញ្ហាប្រឈម, ចំណាត់ការ និង ផែនការសកម្មភាព ព្រមទាំងពេលវេលាអនុវត្តជាក់លាក់។

ក្នុងន័យនេះ គ.ស.ហ សូមគោរពស្នើសុំការសម្រេចជាគោលការណ៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** អនុញ្ញាតឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សហការជាមួយដៃគូអភិវឌ្ឍន៍ និងក្រសួង-ស្ថាប័នពាក់ព័ន្ធរៀបចំ "ក្របខណ្ឌតាមដាននិងវាយតម្លៃ(M&E Framework) នៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥" សម្រាប់ជាធាតុចូលក្នុងការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេច ឬ ផ្តល់ការណែនាំដ៏ខ្ពង់ខ្ពស់ ជាយថាហេតុ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

13-3.20

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ការិយាល័យរដ្ឋបាល ក្រ.សហវ
មកដល់ថ្ងៃទី 12/06/20 ម៉ោង 15:00
លេខ: 2963...
អ្នកទទួល:...
អ្នកប្រគល់:...
បញ្ជូនទៅ:...
20106269.

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
*Nation- Religion- King*

រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
**Council for the Development of Cambodia**

លេខ ២២៤៣/២០ ក.អ.ក

ថ្ងៃ...... ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ. ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០២០

ខុទ្ទកាល័យ ក.ស.ហ.វ.
លេខ: 2005446...
ថ្ងៃទី 16/06/20 ម៉ោង...........
អ្នកប្រគល់:..............................

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ ៖** សំណើសុំដាក់ឆ្លង "ក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥" ក្នុងកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**យោង ៖** - របាយការណ៍កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការពិនិត្យលើ "សេចក្តីព្រាងវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (IDP) ក្នុងឆ្នាំ២០១៧-២០១៨ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០។

**ជូនភ្ជាប់ ៖** សេចក្តីព្រាងក្របខណ្ឌនៃការតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក) បានរៀបចំសេចក្តីព្រាងក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (IDP) យោងតាមស្មារតីនៃកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០។ ក្នុងការរៀបចំក្របខណ្ឌនេះ ក.អ.ក. បានដកពិសោធន៍ និងរៀនសូត្រពីការរៀបចំឯកសារទស្សនទាន និងក្របខណ្ឌតាមដានសមិទ្ធកម្មនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ និងទទួលបានការបណ្តុះបណ្តាលនិងការផ្តល់ធាតុចូលបន្ថែមពីអ្នកជំនាញការជាន់ខ្ពស់ផ្នែកតាមដាននិងវាយតម្លៃ (M&E) របស់អង្គការសហប្រជាជាតិ

ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO) ព្រមទាំងមតិយោបល់របស់អ្នកជំនាញការកម្មវិធីអភិវឌ្ឍន៍សហ-ប្រជាជាតិ (UNDP) ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងឆ្លើយតបនឹងបរិបទរបស់កម្ពុជាផងដែរ។

ក្នុងន័យនេះ ខណៈដែលស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ មិនទាន់ធូរស្បើយនៅឡើយ ខ្ញុំសូមស្នើដាក់ឆ្លងសេចក្តីព្រាងក្របខណ្ឌតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយ IDP ក្នុងកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាកិច្ចប្រជុំមានលក្ខណៈអន្តរក្រសួងស្រាប់ ពិនិត្យនិងផ្តល់យោបល់តែម្តង មុននឹងគោរពជូនប្រមុខរាជរដ្ឋាភិបាលសម្រេច តាមពេលវេលាសមស្រប។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយក-រដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដាក់សេចក្តីព្រាងក្របខណ្ឌនេះ ក្នុងរបៀបវារៈនៃកិច្ចប្រជុំគណៈកម្មា-ធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ ពីខ្ញុំ។

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**
**អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

B. Chin

**ជិន ប៊ុនសឺន**

ចម្លងជូន÷
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.........សហវ.....គសហ

ថ្ងៃ..........ខែ..........ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី.....ខែ..........ឆ្នាំ ២០២០

**ជម្រាបជូន**

**ឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**កម្មវត្ថុ÷** ករណីសំណើសុំឆ្លង "ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥" ក្នុងកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**យោង÷** លិខិតលេខ ២២៤៣/២០ ក.អ.ក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០២០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមទេសរដ្ឋមន្ត្រី** ជ្រាបថា÷ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ) បានពិនិត្យលើខ្លឹមសារនៃ "ក្របខ័ណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥" និងយល់ឃើញថា ក្របខ័ណ្ឌនេះមានលក្ខណៈបច្ចេកទេស ដែលចាំបាច់មានការពិភាក្សា និងការឯកភាព ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាមុន ។ ក្នុងន័យនេះ គ.ស.ហ សូមជូននូវអនុសាសន៍ ដូចខាងក្រោម÷

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាគួរយកសេចក្តីព្រាងនេះ ទៅពិភាក្សាកម្រិតបច្ចេកទេសជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសម្របសម្រួល ដើម្បីកំណត់នូវសូចនាករគន្លឹះដែលមានភាពប្រាកដនិយម និងសមស្រប និង
- សម្រាប់ជំហានបន្ទាប់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអាចដាក់សំណើ ដើម្បីឆ្លងកិច្ចប្រជុំ គ.ស.ហ ទាំងក្របខ័ណ្ឌ និងសូចនាករដែលទទួលបានការឯកភាពពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** ពិនិត្យ និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** ទទួលនូវគារវកិច្ចពីខ្ញុំ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ... សហវ.គសហ

ថ្ងៃ... ខែ... ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ ២០២០

| ខុទ្ទកាល័យសម្តេចតេជោ ( វិមានសន្តិភាព ) | |
|---|---|
| ចូល | លេខ :..................... |
| | ថ្ងៃទី : 23.10.2020 |
| | ម៉ោង : 11h30 |

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** របាយការណ៍លទ្ធផលកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី "ក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥" ។

**យោង៖** ចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០២០ លើលិខិតលេខ ១៧៥០ សហវ.គសហ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២០ ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ, ខ្ញុំសូមគោរពជម្រាបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ នាព្រឹកថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០២០, ខ្ញុំបានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ) ដើម្បីពិនិត្យ និងពិភាក្សាលើ "ក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥ (IDP)" ។ កិច្ចប្រជុំនេះទទួលបានការចូលរួមពី ឯកឧត្តម **ជិន ប៊ុនសៀន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក), ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ, ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ីង ថូរ៉ាក់ស៊ី** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការ ទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងធនាគារជាតិនៃកម្ពុជា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ។ ក្នុងន័យនេះ, ខ្ញុំសូមគោរពរាយការណ៍ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** នូវលទ្ធផលសំខាន់ៗនៃកិច្ចប្រជុំដូចខាងក្រោម៖

តបតាមស្មារតីនៃកិច្ចប្រជុំ គ.ស.ហ នាថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២០, ក.អ.ក បានរៀបចំក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្ត IDP ដោយមានការពិគ្រោះយោបល់ជាមួយគ្រប់តួអង្គពាក់ព័ន្ធ ។ បន្ទាប់ពីការពិភាក្សាយ៉ាងផុសផុល និងល្អិតល្អន់, អង្គប្រជុំបានវាយតម្លៃខ្ពស់លើកិច្ចខិតខំប្រឹងប្រែងក្នុងការរៀបចំក្របខណ្ឌនេះឡើង និងយល់ឃើញថា ក្របខណ្ឌនេះមានភាពគ្រប់ជ្រុងជ្រោយ ដែលអាចធានាការតាមដាន និងវាយតម្លៃការអនុវត្ត IDP ប្រកបដោយប្រសិទ្ធភាព ។ ក្របខណ្ឌតាមដាន និងវាយតម្លៃ ការអនុវត្ត IDP នេះ ប្រើប្រាស់ឧបករណ៍ចំនួន ០៣ គឺ តក្កកម្មអន្តរាគមន៍ (Intervention Logic), ក្របខណ្ឌតក្កកម្ម (Log-Frame) និងទម្រង់គំរូនៃរបាយការណ៍ (Report Template Format) ដោយកំណត់សូចនាករគន្លឹះជា ០៣ កម្រិត រួមមាន៖ (១). **កម្រិតយុទ្ធសាស្ត្រ** មានចំនួន ៣១ សូចនាករ, (២). **កម្រិតវិស័យ** មានចំនួន ៦៩ សូចនាករ, និង (៣). **កម្រិតបច្ចេកទេស** មានចំនួន ៣៦៩ សូចនាករ ។


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

យ៉ាងណាមិញ, អង្គប្រជុំយល់ឃើញថា សូចនាករគន្លឹះសរុបមានចំនួនច្រើន និងអាចបន្ថែមបន្ទុកមិនចាំបាច់ដល់ក្រសួង-ស្ថាប័ន ដែលការណ៍នេះទាមទារការពិនិត្យឡើងវិញផ្អែកលើទិន្នន័យដែលមាន, ភាពជឿទុកចិត្តបាននៃទិន្នន័យ, ភាពចាំបាច់ និងភាពប្រទាក់ក្រឡាគ្នាជាមួយនឹងគោលបំណងគោលនយោបាយដែលបានកំណត់ក្នុង IDP ។

ផ្អែកលើស្មារតីនេះ, អង្គប្រជុំបានផ្តល់ការណែនាំដល់លេខាធិការដ្ឋានដឹកនាំ និងសម្របសម្រួលការ-អនុវត្ត IDP នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដូចខាងក្រោម៖

- ពិនិត្យ និងកែសម្រួលសូចនាករគន្លឹះទាំង ០៣ កម្រិតឱ្យមានលក្ខណៈកាន់តែច្បាស់លាស់, មានភាព-ប្រទាក់ក្រឡា និងផ្អែកលើទិន្នន័យដែលមានស្រាប់,
- អនុវត្តសាកល្បងនូវក្របខណ្ឌនេះក្នុងការវាយតម្លៃវឌ្ឍនភាពពាក់កណ្តាលអាណត្តិ នៃការអនុវត្ត IDP និងរៀបចំរបាយការណ៍តាមដាន និងវាយតម្លៃនៃការអនុវត្ត IDP ពាក់កណ្តាលអាណត្តិ ឆ្នាំ ២០១៥-២០២០ ដោយផ្តោតលើបន្ថែមលើ៖
    ១. ការពិនិត្យឡើងវិញនូវទិសដៅ និងអាទិភាពនៃការជំរុញ និងអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា ក្នុងបរិការណ៍ប្រក្រតីភាពថ្មី (New Normal) ជាពិសេសក្រោយវិបត្តិកូវីដ១៩ ដោយធានាសង្គតិភាព និងភាពប្រទាក់ក្រឡា រវាងគោលនយោបាយ និងយុទ្ធសាស្ត្រ ដែលគ្រោងនឹងបញ្ចប់ នៅឆ្នាំ ២០២១ នេះ ដូចជា៖ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថល, ក្របខណ្ឌគោលនយោ-បាយរដ្ឋាភិបាលឌីជីថល, គោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម, ការធ្វើទំនើបកម្មវិស័យកសិកម្ម ។ល។, និង
    ២. ការកែលម្អក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្ត IDP ដោយផ្អែកលើបទពិសោធន៍នៃការអនុវត្តក្របខណ្ឌនេះ សម្រាប់ការងារតាមដានការអនុវត្ត ក្នុងឆ្នាំបន្តបន្ទាប់ និងបញ្ចប់អាណត្តិ ។

ក្នុងន័យនេះ ដើម្បីធានាប្រសិទ្ធភាព និងភាពគ្រប់ជ្រុងជ្រោយនៃរបាយការណ៍វឌ្ឍនភាពការអនុវត្ត IDP ពាក់កណ្តាលអាណត្តិ, គ.ស.ហ សូមគោរពស្នើសុំការសម្រេចជាគោលការណ៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** *អនុញ្ញាតឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាពន្យារពេលការរៀបចំ និងបញ្ចប់ការរៀបចំរបាយការណ៍តាមដាន និងវាយតម្លៃពាក់កណ្តាលអាណត្តិ សម្រាប់ឆ្នាំ ២០១៥-២០២០ ពីឆមាសទី ១ ឆ្នាំ ២០២១ ដល់ ត្រឹមដំណាច់ឆ្នាំ ២០២១ ។*

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍, ពិនិត្យ និងសម្រេច ឬផ្តល់ការណែនាំដ៏ខ្ពង់ខ្ពស់ ជាយថាហេតុ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

28-10-20

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**